# បណ្ដុំទី

## ស្ដីអំពី:

# ការចាំវស្សារបស់ព្រះសង្ឃពុទ្ធសាសនិក



ការចូលវស្សា ឬ ចាំវស្សា ជាប្រពៃណីរបស់ព្រះសង្ឃពុទ្ធសាសនិកមានតាំងពីជំនាន់ពុទ្ធកាលរៀងមក សម្រាប់ព្រះសង្ឃថេរវាទក្នុងសកល-

លោក មានប្រទេសស្រីលង្កា ប្រទេសថៃ ប្រទេសភូមា ប្រទេសលាវ ព្រមទាំងប្រទេសជាច្រើនផ្សេងទៀតក្នុងនោះមានប្រទេសកម្ពុជាយើងផងដែរ។ រឿងនេះ មានសម្តែងទុកក្នុងគម្ពីរព្រះ-ត្រៃបិដកភាគទី៧ ក្នុងវស្សូបនាយិកក្ខន្ធកៈ ទំព័រ១ ផ្នែកព្រះវិន័យ ។

## ក. មូលហេតុនៃការចូលវស្សា

សម័យនោះ ព្រះមានព្រះភាគទ្រង់គង់នៅវត្តវេឡុវ័នទៀបក្រុងរាជគ្រឹះ។ គ្រានោះឯង ការចាំវស្សាព្រះមានព្រះភាគមិនទាន់បានអនុញ្ញាតដល់

ភិក្ខុទាំងឡាយនៅឡើយទេ។ ភិក្ខុទាំងនោះក៏ចេញដើរទៅកាន់ចារិក ផ្សេងៗអស់ហេមន្តរដូវ ខ្លះអស់គិម្ហរដូវខ្លះ អស់វស្សានរដូវខ្លះ ។ មនុស្សទាំងឡាយក៏ពោលទោសតិះដៀលបន្តុះបង្អាប់ថា ពួកសមណៈជាសាក្យបុត្តិយ៍ មិនសមបើនឹងដើរ (ខុសរដូវកាល) ជាន់ស្មៅស្រស់ ជាន់សត្វល្អិតៗ ឲ្យវិនាសសោះ ។ សូម្បីពួកបរិព្វាជកមានលទ្ធិដទៃជាអ្នកពោលធម៌អាក្រក់ ម្ដេចគង់នឹងសម្ងំឈប់សម្រាកចាំវស្សា ឬ សូម្បីពួកសត្វស្វាបទៀតសោតក៏គង់តែធ្វើសំបុកលើចុងឈើ ហើយសម្ងំឈប់សម្រាកចាំវស្សាដែរ ។ ពេលមនុស្សទាំងឡាយកំពុងលើកទោសបែបនេះ ពួកភិក្ខុទាំងនោះក៏បានឮច្បាស់នឹងត្រចៀកផ្ទាល់ហើយក៏នាំសេចក្ដីនោះទៅក្រាបទូលព្រះសម្ពុទ្ធ ។ ព្រះសាស្ដាទ្រង់ធ្វើ

ធម្មីកថា ត្រាស់ហៅភិក្ខុទាំងឡាយមកអនុញ្ញាតថា "**អនុជា-នាមិ ភិក្ខវេ វស្សំ ឧបគន្តុំ** = ម្នាលភិក្ខុទាំងឡាយតថាគតអនុញ្ញាតឲ្យភិក្ខុចូលវស្សា" ។

## ខ. ការចូលវស្សាឬចាំវស្សាមានពីរគឺ៖

១.បុរិមិកាវស្សា (វស្សាខាងដើម)

២.បច្ឆិមិកាវស្សា (វស្សាខាងចុង១) ។

### សេចក្តីពន្យល់

ការចូលបុរិមិកាវស្សា នៅថ្ងៃ១រោច ខែអា-សាឍ ហើយចេញនៅថ្ងៃពេញបូណ៌មី ខែអស្សុជ

(បើឆ្នាំណាមានអធិកមាស ត្រូវចូលនៅថ្ងៃ ១ រោច ខែទុតិយាសាឍ ព្រោះមានពុទ្ធានុញ្ញាតថា "**អនុជានាមិ ភិក្ខវេ រាជូនំ អនុវត្តិតុំ** = ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យចូលវស្សាទៅតាមការអនុវត្តលើកខែរបស់ព្រះរាជាចុះ" ។ ការចូលបច្ឆិមិកាវស្សា នៅថ្ងៃ១រោច ខែស្រាពណ៍ ហើយចេញនៅថ្ងៃពេញបូណ៌មីខែកត្តិក។ ប្រសិនបើភិក្ខុណាមានធុរៈ មិនបានប្តេជ្ញាអធិដ្ឋានបាលីចូលបុរិមិកាវស្សាទេ ភិក្ខុនោះអាចប្តេជ្ញាអធិដ្ឋានបាលីចូលបច្ឆិមិកាវស្សាក៏បានដែរ ប៉ុន្តែភិក្ខុពុំអាចគេចវេះមិនចូលវស្សាណាមួយជាដាច់ខាត ដូចមានពុទ្ធប្បញ្ញត្តិថា "**ន ភិក្ខវេ វស្សំ ន ឧបគន្តព្វំ យោ ន ឧបគច្ឆេយ្យ អាបត្តិ ទុក្កដស្ស** = ម្នាលភិក្ខុទាំងឡាយភិក្ខុកុំមិនចូលវស្សាឡើយ គឺត្រូវតែចូល

វស្សា ភិក្ខុណាមិនចូលវស្សា ភិក្ខុនោះត្រូវអាបត្តិ-ទុក្កដ" ។

## គ. សត្តាហករណីយ

ភិក្ខុ កាលបើបានប្ដេជ្ញាអធិដ្ឋានចូលវស្សាក្នុងអាវាសណាមួយហើយ ត្រូវស្ថិតនៅក្នុងបរិវេណអាវាសនោះគ្រប់បីខែ គឺមិនត្រូវចេញក្រៅអាវាសនោះឲ្យកន្លងរាត្រីណាមួយឡើយ ដូចមានពុទ្ធប្បញ្ញត្តិថា "ន ភិក្ខវេ វស្សំ ឧបគន្ត្វា បុរិមំ វា តេមាសំ បច្ឆិមំ វា តេមាសំ អវសិត្វា ចារិកា បក្កមិតព្វា យោ បក្កមេយ្យ អាបត្តិ ទុក្កដស្ស =

ម្នាលភិក្ខុទាំងឡាយ ភិក្ខុចូលវស្សាហើយ មិននៅចាំបុរិមិកាវស្សាអស់ខែបី ឬបច្ឆិមិកាវស្សាអស់ខែបីទេ មិនត្រូវចៀសចេញទៅកាន់ចារិកឡើយ, ភិក្ខុណាចៀសចេញទៅត្រូវអាបត្តិទុក្កដ"ៗ ប៉ុន្តែ បើភិក្ខុមានធុរៈចាំបាច់ អាចលើកសត្តាហៈ (សុំច្បាប់ព្រះ) ជាមុនហើយទើបចេញបាន តែត្រូវត្រឡប់មកអាវាសវិញឲ្យទាន់ចន្លោះថ្ងៃ៧ យ៉ាងយូរបំផុតៗ

ឯធុរៈចាំបាច់ដែលភិក្ខុលើកយកមកធ្វើជាមូលហេតុដើម្បីលើកសត្តាហៈនោះគឺៈ

- ភិក្ខុ ភិក្ខុនី សិក្ខមានា សាមណេរ សាមណេរី ឧបាសក ឧបាសិកា ចង់ធ្វើទាន ចង់ស្តាប់ធម៌ ចង់ឃើញ ហើយគេបញ្ជូនបម្រើមក ភិក្ខុ

អាចលើកសត្តាហៈបាន ។

- ភិក្ខុ ភិក្ខុនី សិក្ខមានា សាមណេរ សាមណេរី មាតាបិតា បងប្អូនប្រុសមានជម្ងឺ ឬក៏មានសង្ឃកិច្ចត្រូវបំពេញ ភិក្ខុអាចលើកសត្តាហៈបាន ។

- បងប្អូនស្រី ញាតិ អ្នកធ្វើការឈ្នួល (វេយ្យាវច្ចៈ) មានជម្ងឺ ហើយគេបញ្ជូនបម្រើមកភិក្ខុ អាចលើកសត្តាហៈទៅបាន ។

Wat Prasat Srahkandal Kchhas

# ឃ. វិធីលើកសត្តាហៈនោះគឺ

ភិក្ខុ ត្រូវគ្រងចីពរឆៀងស្មាម្ខាង ចូលទៅថ្វាយបង្គំព្រះ (ព្រះពុទ្ធរូប) អធិដ្ឋានបាលីលើកសត្តាហៈថា "**សចេ មេ អន្តរាយោ នត្ថិ សត្តាហព្ភន្តរេ បុន និវត្តិស្សាមិ** = ប្រសិនគ្មានអន្តរាយកើតមានដល់ខ្ញុំព្រះអង្គទេ ខ្ញុំព្រះអង្គ នឹងវិលត្រឡប់មកអាវាសនេះវិញក្នុងចន្លោះនៃ៧ថ្ងៃ" (សូត្របីដង)។ បើភិក្ខុបានលើកសត្តាហៈបែបនេះហើយចេញទៅ ស្រាប់តែមានឧបសគ្គតាមផ្លូវ ធ្វើឲ្យភិក្ខុមិនអាចត្រឡប់មកអាវាសវិញ ក្នុងចន្លោះនៃ៧ថ្ងៃទេ ភិក្ខុនោះឈ្មោះថាដាច់វស្សា តែមិនត្រូវអាបត្តិ (ទោស ) ឡើយ ។ នៅមានអន្តរាយមួយចំនួនទៀត ដែលធ្វើឲ្យភិក្ខុត្រូវចេញចាកអាវាស

(រត់ចោលវស្សា) តែមិនត្រូវអាបត្តិទេ គឺគ្រាន់តែដាច់វស្សាប៉ុណ្ណោះ។ អន្តរាយទាំងនោះដូចជាសត្វសាហាវបៀតបៀន, សត្វមានពិសបៀតបៀន, ភ្លើងឆេះស្រុក និងទីសេនាសនៈ, ទឹកជន់លិចស្រុក ចោរមកតាំងនៅក្នុងស្រុក, ពួកទាយកជាច្រើនឥតមានសទ្ធាជ្រះថ្លា, ខ្វះចង្ហាន់បិណ្ឌបាត, គ្មានឧបដ្ឋាកដ៏សមគួរ, ស្រីប្រលោមភិក្ខុ ស្រីផ្កាមាសប្រលោមភិក្ខុ, នាងចុល្លកុមារី ប្រលោម ភិក្ខុ, មនុស្សខ្ទើយប្រលោមភិក្ខុ ញាតិប្រលោមភិក្ខុ, ស្តេចប្រលោមភិក្ខុ, ពួកចោរប្រលោមភិក្ខុ, អ្នកលេងប្រលោមភិក្ខុ, ភិក្ខុឃើញកំណប់ទ្រព្យ ភិក្ខុ-សង្ឃបែកគ្នា ។

# ង. ការកំណត់ចាំវស្សាក្នុងសម័យពុទ្ធកាល

ស្រុកភូមិណា ដែលស្ថិតនៅឆ្ងាយដាច់ស្រ-យាល គ្មានវត្តអារាមនៅជិត គេតែងនាំគ្នារៀបចំធ្វើជាសាលានៅកន្លែងណាមួយក្បែរនោះ ហើយនិមន្តភិក្ខុសង្ឃតិច ឬច្រើនអង្គតាមសទ្ធានិមន្ត ឲ្យគង់ចាំវស្សាទីនោះ ដើម្បីងាយស្រួលក្នុងការធ្វើបុណ្យសុន្ទរ៍ទានផ្សេងៗ ។ ភិក្ខុមុននឹងសម្រេចចិត្តទទួលនិមន្តចូលវស្សានៅកន្លែងណាមួយ ត្រូវពិ-និត្យមើលកន្លែងនោះ ឲ្យបានម៉ត់ចត់ជាមុនសិនសឹមទទួលនិមន្ត។ បើពិនិត្យឃើញថា កន្លែងដែលគេនិមន្តឲ្យនៅចាំវស្សានោះសមរម្យ គ្មានចង្អៀតទេ ភិក្ខុគប្បីទទួលនិមន្តចុះ។ ទីកន្លែងដែលព្រះ-

សម្ដេចទ្រង់ហាមមិនឲ្យចូលវស្សានោះ គឺ ក្នុងរូងឈើ, លើប្រគាបឈើ, ក្នុងទីវាលគ្មានសេនាសនៈ, ក្នុងខ្ទមអ្នកតា, ក្រោមឆត្រ, ក្នុងអាងទឹក (និងទឹកន្ទ្រែងមានរង្មើស)។

## ច. ទិដ្ឋភាពនៃការចូលវស្សា

ក្នុងការចូលវស្សារបស់ភិក្ខុសង្ឃ ដែលព្រះ-សម្ដេចទ្រង់អនុញ្ញាត និងបញ្ញត្តទុកតមកនោះ ពុំមានពិធីអ្វីអបរួមផ្សំច្រើនទេ គឺបើកាលណាតិថីចូលវស្សាមកដល់ហើយ ភិក្ខុគ្រាន់តែអធិដ្ឋានបាលីចូលវស្សាប៉ុណ្ណោះជាការស្រេច ប៉ុន្តែក្នុងការ

ចូលវស្សារបស់ភិក្ខុសង្ឃកម្ពុជា គេសង្កេតឃើញមានសកម្មភាព និងពិធីអមគួបផ្សំមួយចំនួន កើតមាននៅពេលជាមួយគ្នានោះដែរ។

ភិក្ខុសាមណេរ ដែលស្នាក់នៅរៀនសូត្រឆ្ងាយពីស្រុកកំណើត ត្រូវបានឈប់សម្រាកចំនួនពីរសប្ដាហ៍មុនថ្ងៃចូលវស្សា ដើម្បីទៅសួរសុខទុក្ខញាតិញោម ឯញាតិញោមក៏បវារណាចតុប្បច្ច័យត្រៀមទុកប្រើប្រាស់ក្នុងឱកាសចូលវស្សាអស់ខែបី។

មុនថ្ងៃចូលវស្សាមកដល់ អាចារ្យ គណៈកម្មការវត្ត តែងដើរប្រកូកប្រកាសដំណឹងអំពីថ្ងៃចូលវស្សា និងសុំឲ្យឧបាសក ឧបាសិកា ទាយកទាយិកាចំណុះជើងវត្ត ជួយបរិច្ចាគចតុប្បច្ច័យតាមកម្លាំងសទ្ធា ដើម្បីឧបត្ថម្ភព្រះសង្ឃដែលនឹង

គង់ចាំវស្សាក្នុងវត្តរបស់ខ្លួននាឆ្នាំនេះ ។

ជិតដល់ថ្ងៃចូលវស្សា ឧបាសក ឧបាសិកា តែងមកកាន់វត្តច្រើនកុះករប្លែកពីធម្មតា ដើម្បីសមាទានសីល ប្រគេនចង្ហាន់ព្រះសង្ឃ បោស-ប្រាសវត្តអារាមសិតទៀនវស្សា ចាត់ចែងសាដក ប្រគេនព្រះសង្ឃ ។ តាមឯកសារនានា បានបញ្ជាក់ថា ព្រះអតីតមហាក្សត្រខ្មែរ ទ្រង់មានព្រះរាជសទ្ធាជ្រះថ្លា បំពេញព្រះរាជកុសលក្នុងឱកាសព្រះសង្ឃចូលវស្សានេះដែរ ដូចជាទ្រង់ឲ្យធ្វើពិធីខ្វាន់នាគ ពិធីសិតទៀនវស្សា និងពិធីនិមន្តទេវរូបចូលវស្សាជាដើម ។

នៅល្ងាចថ្ងៃ១៥កើត ខែអាសាឍ គេឃើញឧបាសក ឧបាសិកា មកជួបជុំគ្នាក្នុងវត្ត ហែទៀន

វស្សា ហៅសាដក និងគ្រឿងសម្ភារៈប្រទក្សិណព្រះវិហារនិមន្តព្រះសង្ឃចម្រើនព្រះបរិត្ត បវារណាព្រះសង្ឃចូលព្រះវស្សា វេរទៀនវស្សាសាដក ប្រគេនព្រះសង្ឃ។ លុះព្រឹកឡើង មានការប្រគេនភត្តាហារចំពោះព្រះសង្ឃទៀត ។

នៅល្ងាចថ្ងៃ១រោច ខែអាសាឍ គេឃើញព្រះសង្ឃនិមន្តជួបជុំនៅក្នុងព្រះវិហារ។ ព្រះសង្ឃជាមហាថេរ បានប្រកាសអំពីការចូលវស្សា និងធ្វើការក្រើនរំលឹកអំពីក្រឹត្យវិន័យ ដែលទាក់ទងដល់ការចូលវស្សាថា "**ឥមស្មឹ អាវាសេ ឥមំ តេមាសំ វស្សំ ឧបេមិ ។ ទុតិយម្បិ ឥមស្មឹ... វស្សំ ឧបេមិ, តតិយម្បិ ឥមស្មឹ... វស្សំ ឧបេមិ** = ខ្ញុំសូមនៅចាំវស្សាអស់ខែបីក្នុងអាវាសនេះ អស់វារៈពីរដងផង

# *អស់ការៈបីដងផង” ជាកិច្ចបញ្ចប់នៃពិធីចូលវស្សា។*

(ដកស្រង់សម្រួលពីសៀវភៅយល់ដឹងពីការចូលវស្សា ដង្ហែទៀនវស្សា និងសាដក ព្រះមហាធម្មលង្កាកោ ចាន់ សុជន និងអធិប្បាយពន្យល់ ដោយព្រះមហាធម្មលង្កាកោ ចាន់ សុជន)

លោកគ្រូព្រះមហាធម្មលង្កាកោ **ចាន់ សុជន**

ប្រធានកម្មវិធីផាទីសំឡេងព្រះធម៌

**វត្តប្រាសាទស្រះកណ្ដាល(ខ្វាស់)**

បានពិនិត្យ

និងឯកភាព

*ធ្វើនៅវត្តប្រាសាទស្រះកណ្ដាល(ខ្វាស់)*
*ថ្ងៃ១៥កើត ខែអាសាឍ ព.ស.២៥៥៨*
*ត្រូវនឹងថ្ងៃសុក្រ ទី១១ ខែកក្កដា ឆ្នាំ២០១៤*